# សិទ្ធិមូលដ្ឋានរបស់អ្នកជម្ងឺដែលបានមកវះកាត់នៅមណ្ឌលវះកាត់នៃរដ្ឋ Minnesota

# ច្បាប់ឆ្នាំ 2004 នៃរដ្ឋ Minnesota

### 144.651 អ្នកជម្ងឺ និងអ្នកស្នាក់នៅ នៃមណ្ឌលថែទាំសុខភាព; ច្បាប់សិទ្ធិមូលដ្ឋាន

អនុផ្នែក 1 ។ **គោលគំនិតរបស់ច្បាប់** នេះគឺជាស្មារតីនៃច្បាប់ និងគោលបំណងនៃ ផ្នែកនេះគឺដើម្បីលើកកម្ពស់ផលប្រយោជន៍ សុខភាពរបស់អ្នកជម្ងឺ និងអ្នកស្នាក់នៅនៃមណ្ឌល ថែទាំសុខភាព ។ គ្មាន មណ្ឌលថែទាំសុខភាពណា អាចតម្រូវឱ្យអ្នកជម្ងឺ ឬអ្នកស្នាក់នៅ បោះបង់សិទ្ធិទាំងនេះចោលថ្នូរនឹងលក្ខខណ្ឌ ចូលក្នុងមណ្ឌលបានឡើយ ។ អ្នកអាណាព្យាបាល ឬអ្នកថែទាំងអ្នកជម្ងឺ ឬអ្នកស្នាក់នៅ ក្នុងករណី អវត្តមានអ្នកអាណាព្យាបាល ឬ អ្នកថែទាំបុគ្គលមានប្រយោជន៍ អាចស្វែងរកការអនុវត្តសិទ្ធិទាំងនេះ ក្នុងនាម អ្នកជម្ងឺ ឬអ្នកស្នាក់នៅបាន ។ បុគ្គលមានប្រយោជន៍ក៏អាច ស្វែងរកមការអនុវត្តសិទ្ធិទាំងនេះបានផងដែរក្នុងនាមអ្នកជម្ងឺ ឬ អ្នកស្នាក់នៅ ដែលមានអ្នកអាណាព្យាបាល ឬអ្នកថែទាំ តាមរយៈភ្នាក់ងាររដ្ឋបាលឬក្នុងតុលាការស្រុកដែលមានយុត្តាធិការលើការគ្រប់គ្រង និងការថែទាំ ។ ការព្យួរលទ្ធផលនៃការអនុវត្តបន្តការថែទាំសុខភាពអាច ដោយចេតនាសុចរិត អនុវត្តតាមការណែនាំរបស់អ្នកអាណាព្យាបាល ឬអ្នកថែទាំ ។ ស្មារតី នៃផ្នែកនេះ គឺថាសិទ្ធិពលរដ្ឋ និងសេរីភាពខាងសាសនារបស់អ្នកជម្ងឺរួមទាំង សេរីភាពធ្វើសេចក្តីសម្រេចផ្ទាល់ខ្លួន និងសេរីភាពទទួលស្គាល់ជម្រើសដែលមាន មិនត្រូវ បំពានឡើយ ហើយមណ្ឌលត្រូវលើកទឹកចិត្ត និងជួយឱ្យបានពេញទំហឹង តាមដែលអាចធ្វើបាន ។

**និយមន័យ**

អនុផ្នែក ។ 2. **និយមន័យ ។** សម្រាប់គោលបំណងនៃអនុផ្នែក 4 ដល់ 9 12 13 15 16 និង 18 ដល់ 20 "អ្នកជម្ងឺ" សំដៅដល់បុគ្គល ដែលទទួលសេវាថែទាំសុខភាព នៅមណ្ឌលវះកាត់អ្នកជម្ងឺ ។

អនុផ្នែក ។ 4. **ព័ត៌មានអំពីសិទ្ធិ ។** នៅខណៈទទួលឱ្យចូល អ្នកជម្ងឺត្រូវបានប្រាប់អំពីសិទ្ធិស្របច្បាប់ដើម្បីការពារពួកគេ ក្នុងអំឡុងពេលនៃការស្នាក់នៅរបស់ពួកគេនៅក្នុងមណ្ឌល ឬពេញរយៈពេលនៃការព្យាបាលជម្ងឺ និងស្ថិតក្នុងសមាគមន៍ ដែលត្រូវបានរៀបរាប់ភ្ជាប់ជាមួយសេចក្តីប្រកាសនៃសិទ្ធិដែលអនុវត្តបាន និងការទទួលខុសត្រូវកំណត់នៅក្នុងផ្នែកនេះ ។ ការស្នាក់នៅសមរម្យត្រូវផ្តល់ឱ្យ សម្រាប់បុគ្គលដែលមានការទំនាក់ទំនងមិនសមស្រប និងសម្រាប់បុគ្គលដែល និយាយក្រៅពីភាសាអង់គ្លេស ។ គោលនយោបាយរបស់មណ្ឌលបច្ចុប្បន្ននេះការរកឃើញរបស់អធិការកិច្ច នៃអាជ្ញាធរសុខភាពរដ្ឋ និងមូលដ្ឋាន និងសេចក្តីថ្លែងការពន្យល់បន្ថែមទៀតអំពីសិទ្ធិទាំងនេះ ត្រូវផ្តល់ជូនចំពោះ អ្នកជម្ងឺ អ្នកអាណាព្យាបាល ឬអ្នកតំណាងដែលគេជ្រើសរើស តាមរយៈសំណើមានហេតុផល ដល់រដ្ឋបាលឬបុគ្គលិកដែលបានចាត់តាំងផ្សេងទៀត ស្របតាមជំពូកទី 13 ច្បាប់ទិន្នន័យអនុវត្តន៍ និងផ្នែកទី 626.557 ទាក់ទងនឹង ជនងាយរងគ្រោះ ។

អនុផ្នែក ។ 5. **ការព្យាបាល ដោយសមរម្យ ។** អ្នកជម្ងឺមានសិទ្ធិទទួលបានការព្យាបាល ដោយសមរម្យគួរសម ដោយបុគ្គលិក ឬបុគ្គលផ្តល់សេវាកម្មថែទាំសុខភាពក្នុងមណ្ឌល ។

អនុផ្នែក ។ 6. **ការថែទាំសុខភាពសមស្រប ។** អ្នកជម្ងឺត្រូវមានសិទ្ធិ ទទួលបាន ការមើលថែទាំជម្ងឺ និងបុគ្គលដោយសមស្រប ផ្អែកលើតម្រូវការរបស់បុគ្គល ។

អនុផ្នែក ។ 7. **អត្តសញ្ញាណរបស់គ្រូពេទ្យ ។** ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និងអ្វីដែលសំខាន់ផ្សេងទៀត បើមាន របស់គ្រូពេទ្យដែលទទួលខុសត្រូវ សម្របសម្រួលមើលថែទាំអ្នកជម្ងឺត្រូវសរសេរហើយផ្តល់ជូនអ្នកជម្ងឺ ។ ក្នុងករណីដែល ការព្យាបាលមិនសមរម្យ ដូចបានកត់ត្រាទុកដោយគ្រូពេទ្យពិនិត្យជម្ងឺនៅក្នុងសៀវភៅរបាយការណ៍របស់អ្នកជម្ងឺ ព័ត៌មាននេះត្រូវផ្តល់ឲ្យអ្នកអាណាព្យាបាលរបស់អ្នកជម្ងឺ ឬបុគ្គលផ្សេងទៀត ដែលត្រូវបានចាត់តាំងជាតំណាងអ្នកជម្ងឺ ។

អនុផ្នែក ។ 8. **ទំនាក់ទំនងជាមួយ នឹងសេវាសុខភាពផ្សេងទៀត ។** អ្នកជម្ងឺដែលទទួលសេវាថែទាំពីអ្នកផ្តល់ខាងក្រៅ ត្រូវបានផ្តល់សិទ្ធិ អាស្រ័យលើសំណើឲ្យប្រាប់ពីអត្តសញ្ញាណនៃអ្នកផ្តល់សេវានោះ ។ ត្រូវមានព័ត៌មានដូចជាឈ្មោះអ្នកផ្តល់សេវាខាងក្រៅ នោះ អាសយដ្ឋាន និងរៀបរាប់អំពីសេវាកម្មដែលត្រូវបានផ្តល់ឲ្យនោះ ។ ក្នុងករណីដែលការពិនិត្យជម្ងឺមិនអាចធ្វើបាន ដូចបានកត់ត្រាទុកដោយគ្រូពេទ្យពិនិត្យនៅក្នុងរបាយការណ៍ថែទាំរបស់អ្នកជម្ងឺ ព័ត៌មាននេះត្រូវផ្តល់ទៅឲ្យអ្នកអាណាព្យាបាលរបស់អ្នកជំងឺ ឬបុគ្គលផ្សេងទៀតដែលត្រូវបានចាត់តាំង ជាអ្នកតំណាងរបស់អ្នកជម្ងឺ ។

អនុផ្នែក ។ 9. **ព័ត៌មានអំពីការព្យាបាល ។** អ្នកជម្ងឺនឹងត្រូវផ្តល់ឲ្យនូវការបំពេញដោយគ្រូពេទ្យពិនិត្យជម្ងឺរបស់ពួកគេនិងស្ថានព័ត៌មានភាពបច្ចុប្បន្ន ទាក់ទងនឹង រោគសញ្ញា ការព្យាបាលការប្រែប្រួល គ្រោះថ្នាក់ និងជោគវាសនារបស់អ្នកជម្ងឺ ដែលជាតម្រូវការកាតព្វកិច្ចផ្លូវច្បាប់របស់គ្រូពេទ្យពិនិត្យដើម្បីបង្ហាញ ។ ព័ត៌មាននេះត្រូវសរសេរជាភាសា និងអត្ថន័យ ដែលអ្នកជម្ងឺអាចយល់ដឹងបាន ។ អ្នកជម្ងឺអាចត្រូវរួមដំណើរ ដោយសមាជិក គ្រួសារ ឬ អ្នកតំណាងដែលបានជ្រើសរើសផ្សេងទៀត។ ព័ត៌មាននេះត្រូវមានព័ត៌មានស្តីពីការព្យាបាល ឬ លទ្ធសំខាន់ៗនៃទស្សនៃការព្យាបាល និង ការប្រែប្រួលរបស់វា ។ ក្នុងករណីដែល ការព្យាបាលមិនអាចពិនិត្យបាន ដូចកត់ត្រាទុកដោយ គ្រូពេទ្យពិនិត្យនៅក្នុងរបាយការណ៍សុខភាពរបស់អ្នកជម្ងឺ ព័ត៌មាននេះត្រូវផ្តល់ទៅឲ្យអ្នកអាណាព្យាបាលរបស់អ្នកជម្ងឺ ឬបុគ្គលផ្សេងទៀតដែលត្រូវបានចាត់តាំងជាអ្នកតំណាងរបស់អ្នកជម្ងឺ ឬអ្នកស្នាក់នៅ ។
បុគ្គលនីមួយៗមានសិទ្ធិបដិសេធចំពោះព័ត៌មាននេះ ។

អ្នកជម្ងឺទាំងឡាយណាមានការឈឺចាប់ដោយ ជម្ងឺមហារីកដោះណាមួយត្រូវជូនព័ត៌មានទាំងស្រុង ឲ្យបានមុខពេល ឬក្នុងអំឡុងពេលនៃការទទួលឲ្យចូល និងក្នុងអំឡុងពេលនៃការស្នាក់នៅរបស់គេ នូវរាល់ការប្រែប្រួលកើតឡើងដោយវិធីសាស្រ្តព្យាបាលដែលគ្រូពេទ្យពិនិត្យគួយល់ដឹងរួមមានការវះកាត់ ការព្យាបាលដោយធាតុវិទ្យុសកម្ម ឬ chemotherapeutic ឬការព្យាបាលរួមបញ្ចូលគ្នា និងគ្រោះថ្នាក់ដែលអាចមានចំពោះវិធីសាស្រ្តនីមួយៗ ។

អនុផ្នែក ។ 12. **សិទ្ធិបដិសេធការថែទាំ ។** អ្នកជម្ងឺដែលមានសមត្ថភាពត្រូវមានសិទ្ធិបដិសេធការព្យាបាលអាស្រ័យលើព័ត៌មានដែលបានតម្រូវក្នុងអនុផ្នែកទី 9 ។ ក្នុងករណីដែល អ្នកជម្ងឺគ្មានសមត្ថភាពយល់ដឹងពីកាលៈទេសៈ ប៉ុន្តែមិនត្រូវបានវិនិច្ឆ័យជាអសមត្ថភាព ឬក្នុងករណីដែលលក្ខខណ្ឌតម្រូវផ្នែកច្បាប់កម្រិតសិទ្ធិ បដិសេធការព្យាបាល លក្ខខណ្ឌ និងកាលៈទេសៈនោះត្រូវកត់ត្រាទុកទាំងស្រុងដោយគ្រូពេទ្យពិនិត្យ នៅក្នុងរបាយការណ៍សុខភាព អ្នកជម្ងឺ ។

អនុផ្នែក ។ 13. **ការស្រាវជ្រាវពិសោធ ។** ការជូនដំណឹងយល់ព្រមជាលាយលក្ខណ៍អក្សរ ត្រូវទទួលបានមុនពេល អ្នកជម្ងឺចូលរួមក្នុងការស្រាវជ្រាវពិសោធ ។ អ្នកជម្ងឺមានសិទ្ធិបដិសេធក្នុងការចូលរួមស្រាវជ្រាវពិសោធនេះ ។ ទាំងការយល់ព្រម និងបដិសេធ ត្រូវកត់ត្រាទុកក្នុងរបាយការណ៍ថែទាំបុគ្គល ។

អនុផ្នែក ។ 15. **ការសម្ងាត់ការព្យាបាល ។** អ្នកជម្ងឺត្រូវមានសិទ្ធិទទួលបានការគោរព និងភាពឯកជន ទាក់ទងនឹងការពិនិត្យព្យាបាលជម្ងឺរបស់គេ និងកម្មវិធីថែទាំផ្ទាល់ខ្លួន ។ ការពិភាក្សាលើករណី ការប្រឹក្សា ការពិនិត្យ និងការព្យាបាលគឺសុទ្ធតែជាការសម្ងាត់ ហើយត្រូវធ្វើឡើងដោយមានការប្រុងប្រយ័ត្នក្នុងការនិយាយ ។ ភាពឯកជនត្រូវបានគោរពក្នុងពេលចូលបង្គន់ងូតទឹក និងសកម្មភាពអនាម័យផ្ទាល់ខ្លួនផ្សេងទៀត លើកលែងតែជាតម្រូវការសុវត្ថិភាព ឬជាជំនួយដល់អ្នកជម្ងឺ ។

អនុផ្នែក ។ 16. **ការសម្ងាត់របាយការណ៍ ។** របាយការណ៍ពិនិត្យជម្ងឺនិងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកជម្ងឺ ត្រូវទុកជាការសម្ងាត់ ហើយអាចត្រូវយកព្រម ឬបដិសេធបញ្ចេញព័ត៌មានទាំងនេះទៅបុគ្គលណាម្នាក់ នៅខាងក្រៅមណ្ឌលបាន ។ ការថតចម្លងរបាយការណ៍ និងព័ត៌សរសេរចេញពីរបាយការណ៍ត្រូវធ្វើឲ្យស្របតាមអនុផ្នែកនេះ និងផ្នែកនេះ 144.335 ។ សិទ្ធិនេះមិនអនុវត្ត ចំពោះការស៊ើបអង្កេត លើពាក្យបណ្តឹង និងការត្រួតពិនិត្យដោយក្រសួងសុខភាព ឡើយក្នុងករណីតម្រូវឲ្យតតីយជនទាក់ទងនឹងកិច្ចសន្យាទូរទាត់ ឬក្នុងករណីផ្សេង ដែលកំណត់ដោយច្បាប់

អនុផ្នែក ។ 18. **សេវាកម្មឆ្លើយតប ។** អ្នកជម្ងឺមានសិទ្ធិទទួលបានការឆ្លើយតបដ៏ត្រឹមត្រូវនិងមានហេតុផលច្បាស់លាស់ចំពោះសំណួរ និងសំណូមពររបស់ពួកគេ ។

អនុផ្នែក ។ 19. **ភាពឯកជនផ្ទាល់ខ្លួន ។** អ្នកជម្ងឺមានសិទ្ធិត្រូវបានពិចារណាគ្រប់យ៉ាងអំពីភាពឯកជន បុគ្គលភាព និងអត្តសញ្ញាណវប្បធម៌របស់អ្នកជម្ងឺ ដែលទាក់ទងនឹងសង្គម សាសនា និងទស្សនៈរបស់គេ ។ បុគ្គលិកមណ្ឌលត្រូវគោរព ភាពឯកជននៃ បន្ទប់ស្នាក់នៅឯកជនរបស់អ្នកជម្ងឺ ដោយត្រូវគោះទ្វារមុនចូលក្នុងបន្ទប់ លើកលែងតែក្នុងករណីបន្ទាប់ ឬករណីមិនអាចពិនិត្យបានយ៉ាងជាក់លាក់ប៉ុណ្ណោះ ។

អនុផ្នែក ។ 20. **ការតវ៉ា ។** អ្នកជម្ងឺត្រូវបានជម្រុញលើកទឹកចិត្តឲ្យ តាមរយៈការស្នាក់នៅក្នុងមណ្ឌល ឬរយៈពេលនៃការព្យាបាលរបស់គេ ឲ្យយល់ដឹង និងអនុវត្តសិទ្ធិជាអ្នកជម្ងឺ និងជាពលរដ្ឋរបស់គេ ។ អ្នកជម្ងឺអាចតវ៉ា និងផ្តល់យោបល់ក្នុងការផ្លាស់ប្តូរគោលនយោបាយ និងសេវាកម្ម ចំពោះបុគ្គលិកមណ្ឌល និងជម្រើសផ្សេងទៀតរបស់គេ រួចផុតពីចូលច្រៀតជ្រែក ការគំរាមកំហែង ការរើសអើង ឬការសងសឹក រួមទាំងព្យាបាទលើកការមិនភ្ជាប់ផងដែរ ។ ការជូនដំណឹងនៃនីតិវិធីតវ៉ា ក្នុងមណ្ឌល ឬកម្មវិធី ក៏ដូចជាអាសយដ្ឋាន និងលេខទូរស័ព្ទសម្រាប់ការិយាល័យទទួលពាក្យបណ្តឹងសុភាពនិងបរិផណគិលានុបដ្ឋាយិកា ពលរដ្ឋ អនុឡោមតាមច្បាប់ស្តីពីពលរដ្ឋចាស់ជរាអាមេរិក 1] ផ្នែកទី 307(a)(12) ត្រូវបិទនៅកន្លែងអាចមើលបាន ។

ការអនុវត្តតាមដោយការមកព្យាបាលជម្ងឺនៅមណ្ឌលវះកាត់2] តាមផ្នែកទី 144.691 និងការអនុវត្តតាមដោយអង្គការថែរក្សាសុខភាព តាមផ្នែកទី 62D.11 ត្រូវបានសន្មត់ថាបានអនុវត្តតាមលក្ខខណ្ឌ សម្រាប់ការសរសេរនីតិវិធីតវ៉ាផ្ទៃក្នុង

**បើអ្នកមានបណ្ដឹងតវ៉ាអំពី ភ្នាក់ងារ ឬបុគ្គលផ្ដល់សេវារៈកាត់ជម្ងឺ  អ្នកអាចហៅទូរស័ព្ទ សរសេរ ឬមកកាន់ការិយាល័យសម្របសម្រួលពាក្យបណ្ដឹងនៃរដ្ឋ MINNESOTA នៃក្រសួងសុខភាព ។ អ្នកក៏អាចទាក់ទង សេវាកម្មថែទាំពលរដ្ឋរយៈពេលវែង បានផងដែរ ។**

**ការិយាល័យទទួលបន្ទុកសម្រួលបណ្ដឹង  ផ្នែកសុខាភិបាល**

(651) 201-4201

1-800- 369-7994

ទូរសារ៖ (651) 281-9796

**អាសយដ្ឋានប៉ុស្ដិ៍៖**

មន្ទីរសុខាភិបាល Minnesota

ការិយាល័យទទួលបន្ទុក សម្រួលបណ្ដឹងផ្នែកសុខាភិបាល

ផ្ទះលេខ 85 កន្លែងទីប្រាំពីរភាគខាងកើត បន្ទប់លេខ 300

ប្រអប់សំបុត្រលេខ 64970

ផ្លូវផូល (Paul) មីនណេសូតា (Minnesota) 55164-0970

**មន្ត្រីចាត់តាំងផ្នែកអង្កេត និងទទួលបណ្ដឹងផ្នែកការថែទាំដែលមានរយៈពេលយូរអង្វែង**

(651) 431-2555

1-800-657-3591

ទូរសារ៖ (651) 431-7452

**អាសយដ្ឋានប៉ុស្ដិ៍៖**

មន្ត្រីចាត់តាំងផ្នែកអង្កេតនិងទទួលបណ្ដឹងផ្នែកការថែទាំដែលមានរយៈពេលយូរអង្វែង

ប្រអប់សំបុត្រលេខ 64971

ផ្លូវផូល (Paul), MN 55164-0971